## មាតិកា


ឧទ្ទិសស្នាដៃ ........ i
សេចក្តីថ្លែងអំណរព្រះគុណនិងអរគុណ ........ ii
អំណះអំណាង ........ iii
អក្សរកាត់ ........ iv
មូលន័យសង្ខេប ........ v
មូលន័យសង្ខេបជាភាសាបរទេស ........ vii
សារណាសង្ខេប ........ viii
សារណាសង្ខេបជាភាសាបរទេស ........ x
អារម្ភកថា ........ xi


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៣
៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣
៤. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ........ ៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៥


## ជំពូកទី១
## ទស្សនាទានស្តីពីព្រះពុទ្ធសាសនានៅកម្ពុជា


**១.១. និយមន័យ "គ្រប់គ្រង"** ........ ៧
**១.២. គោលការណ៍គ្រប់គ្រងសម្រាប់ផ្នែកអាណាចក្រ** ........ ៨
១.២.១. ការងាររបស់អ្នកគ្រប់គ្រង ........ ៨
១.២.២. ការគ្រប់គ្រងការងារ ........ ៩
១.២.៣. ការគ្រប់គ្រងមនុស្ស ........ ៩
១.២.៤. អ្នកគ្រប់គ្រងផលិតផលនិងការប្រតិបត្តិ ........ ៩
**១.៣. ជំនាញអ្នកគ្រប់គ្រង** ........ ១០
១.៣.១. ជំនាញខាងបច្ចេកទេស ........ ១០
១.៣.២. ជំនាញខាងការស្គាល់មនុស្ស ........ ១០

១.៣.៣. ជំនាញខាងគំនិត ..... ១០
**១.៤. កិច្ចការរបស់អ្នកគ្រប់គ្រង** ..... ១១
**១.៥. គោលគំនិតសម្រាប់អ្នកគ្រប់គ្រង** ..... ១២
១.៥.១. យុទ្ធសាស្ត្រក្នុងការងាររបស់អ្នកគ្រប់គ្រង ..... ១២
១.៥.២. ទស្សនៈសម្រាប់អ្នកគ្រប់គ្រង ..... ១២
១.៥.៣. អ្នកគ្រប់គ្រងដែលពឹងលើសមត្ថភាពខ្លួន ..... ១២
**១.៦. ទសពិធរាជធម៌១០យ៉ាងដែលអ្នកដឹកនាំ អ្នកគ្រប់គ្រងត្រូវមាន** ..... ១៣
**១.៧. គុណសម្បត្តិរបស់អ្នកដឹកនាំ** ..... ១៦
**១.៨. អ្នកដឹកនាំគ្រប់គ្រងត្រូវដឹងអ្វីខ្លះ?** ..... ២០
**១.៩. ព្រះពុទ្ធសាសនា** ..... ២៥
១.៩.១. តើព្រះពុទ្ធជានរណា? ..... ២៧
**១.១០. ការវិវត្តព្រះពុទ្ធសាសនានៅអាស៊ីអាគ្នេយ៍** ..... ៣២
**១.១១. ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា** ..... ៣៦
១.១១.១. ព្រះពុទ្ធសាសនានៅសម័យនគរភ្នំ ..... ៣៦
១.១១.២. ព្រះពុទ្ធសាសនានៅសម័យចេនឡា ..... ៣៨
១.១១.៣. ព្រះពុទ្ធសាសនានៅសម័យអង្គរ ..... ៤០
១.១១.៤. ព្រះពុទ្ធសាសនានៅសម័យកណ្ដាល ..... ៤១
១.១១.៥. ព្រះពុទ្ធសាសនានៅសម័យអាណានិគមនិយមបារាំង ..... ៤៣
១.១១.៦. ព្រះពុទ្ធសាសនានៅសម័យសង្គមរាស្ត្រនិយម ..... ៤៤
១.១១.៧. ព្រះពុទ្ធសាសនានៅសម័យសាធារណៈរដ្ឋខ្មែរ ..... ៤៧
១.១១.៨. ព្រះពុទ្ធសាសនាសម័យខ្មែរក្រហម ..... ៤៩
១.១១.៩. ព្រះពុទ្ធសាសនានៅកម្ពុជាក្រោយឆ្នាំ១៩៧៩ ..... ៤៩
**១.១២. ការប្រតិបត្តិព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ** ..... ៥៣
**១.១៣. មូលដ្ឋានគ្រឹះនៃការអប់រំរបស់ព្រះពុទ្ធសាសនា** ..... ៥៥

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់ព្រះសង្ឃក្នុងវិស័យព្រះពុទ្ធសាសនា

**២.១. ទិដ្ឋភាពរួមរបស់ក្រុងដូនកែវ** ..... ៥៨
**២.២. សាលាអនុគណក្រុងដូនកែវ** ..... ៦០
**២.៣. រចនាសម្ព័ន្ធគ្រប់គ្រងសាលាអនុគណក្រុងដូនកែវ** ..... ៦០

**២.៤. សមាសភាពនិងតួនាទីរបស់មន្ត្រីសង្ឃក្រុងជួនកែវ ........................ ៦១**
២.៤.១. តួនាទីនិងភារកិច្ចរបស់ព្រះអនុគណក្រុង ........................ ៦២
២.៤.២. តួនាទីនិងភារកិច្ចរបស់ព្រះវិន័យធរអនុគណ ........................ ៦៦
២.៤.៣ តួនាទីនិងភារកិច្ចរបស់ព្រះធម្មធរអនុគណ ........................ ៦៧
២.៤.៤. តួនាទីនិងភារកិច្ចរបស់ព្រះសមុហ៍អនុគណ ........................ ៦៧
២.៤.៥. តួនាទីនិងភារកិច្ចរបស់ព្រះលេខាធិការអនុគណ ........................ ៦៨
**២.៥. កតិកាសម្រាប់គ្រប់គ្រងវត្តអារាម ........................ ៦៨**
**២.៦. តួនាទីនិងភារកិច្ចគណៈសង្ឃវត្ត ........................ ៧២**
២.៦.១. តួនាទីនិងភារកិច្ចរបស់ព្រះចៅអធិការ ........................ ៧២
២.៦.២. តួនាទីនិងភារកិច្ចព្រះគ្រូសូត្រស្តាំ ........................ ៧៨
២.៦.៣. តួនាទីនិងភារកិច្ចព្រះគ្រូសូត្រឆ្វេង ........................ ៧៨
២.៦.៤. តួនាទីនិងភារកិច្ចព្រះវិន័យធរវត្ត ........................ ៧៩
២.៦.៥. តួនាទីនិងភារកិច្ចលេខាវត្ត ........................ ៧៩
**២.៧. ស្ថិតិព្រះសង្ឃក្នុងក្រុងជួនកែវ ........................ ៨០**
**២.៨. តួនាទីនិងភារកិច្ចរបស់អាចារ្យវត្ត ........................ ៨៦**
២.៨.១. វិជ្ជាសម្បត្តិ ........................ ៨៧
២.៨.២. មានសមត្ថភាពនិងឈ្លាសវៃក្នុងការដឹកនាំ ........................ ៨៨
២.៨.៣. មានសម្ដីវោហារប៉ិនប្រសប់ ........................ ៨៩
២.៨.៤. មានទំនាក់ទំនងល្អជាមួយបរិស័ទ ........................ ៩០
**២.៩. ទំនាក់ទំនងរវាងបព្វជិតនិងឃរាវាស ........................ ៩១**
២.៩.១. តួនាទីព្រះសង្ឃចំពោះពុទ្ធបរិស័ទ ........................ ៩២
២.៩.២. តួនាទីរបស់ពុទ្ធបរិស័ទចំពោះព្រះសង្ឃ ........................ ៩៥
២.៩.៣. ការប្រតិបត្តិរបស់ព្រះសង្ឃនិងគ្រហស្ថ ........................ ៩៧
២.៩.៤. ការអប់រំព្រះបរិយត្តិធម៌ ........................ ១០៣
២.៩.៥. ការអប់រំព្រះកម្មដ្ឋានឬវិបស្សនាធុរៈ ........................ ១០៤

## ជំពូកទី៣

## ការចូលរួមអភិវឌ្ឍសង្គមតាមបែបព្រះពុទ្ធសាសនា

**៣.១. ការចូលរួមរបស់សាលាអនុគណក្រុងក្នុងកិច្ចការអប់រំសីលធម៌សង្គម ...... ១០៦**
៣.១.១. សីលធម៌និងន័យមូលដ្ឋានរបស់មនុស្សជាតិ ........................ ១០៨

៣.១.២. ព្រះពុទ្ធសាសនានិងការទទួលខុសត្រូវសង្គម ............ ១០៩
**៣.២. ការចូលរួមស្ថាបនាសមិទ្ធផលនានា** ............ ១១២
៣.២.១. ការចូលរួមក្នុងវិស័យសុខាភិបាល ............ ១១៣
៣.២.២. ការដឹកនាំពុទ្ធបរិស័ទក្នុងកិច្ចការបរិស្ថាន ............ ១១៥
៣.២.៣. ការអប់រំក្នុងសហគមន៍ ............ ១១៧
៣.២.៤. ការចូលរួមក្នុងវិស័យអប់រំ ............ ១១៩
៣.២.៥. ការចូលរួមអភិរក្សវប្បធម៌ជាតិ ............ ១២២
**៣.៣. ការចូលរួមអភិវឌ្ឍជាតិ** ............ ១២៣
៣.៣.១. ព្រះពុទ្ធសាសនាជាសម្បត្តិជាតិ ............ ១២៥
៣.៣.២. សារៈសំខាន់នៃព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ ............ ១២៦
**សេចក្តីសន្និដ្ឋាន** ............ ១២៨
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

| | |
|---|---|
| គ.ស. | គ្រិស្តសករាជ |
| ព.ស. | ពុទ្ធសករាជ |
| -ដ- | ដដែល |
| ដ.ឯ.ម. | ដូចឯកសារមុន |
| ព.ស.វ. | ពុទ្ធសតវត្សរ៍ |
| ស.វ. | សតវត្សរ៍ |
| ទី.ន | គម្ពីរទីឃនិកាយ |
| ម.ន | គម្ពីរមជ្ឈិមនិកាយ |

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវលើប្រធានបទស្ដីពី"ការគ្រប់គ្រងនិងការប្រតិបត្តិព្រះពុទ្ធសាសនានៅកម្ពុជា" ករណីសិក្សាក្រុងដូនកែវ ខេត្តតាកែវ ពីឆ្នាំ២០១៤ ដល់ ២០១៩ ដែលបានលើកយកមកសិក្សានេះ មានគោលបំណងដើម្បីបង្ហាញថាព្រះពុទ្ធសាសនាបានចូលរួមយ៉ាងសកម្មក្នុងការកសាងសាមគ្គីភាពក្នុងសង្គម បង្ហាញអំពីតួនាទីរបស់ព្រះសង្ឃក្នុងការរៀបចំសង្គមសង្ឃឱ្យមានសេចក្ដីថ្លៃថ្នូរ និងដើម្បីបង្ហាញពីការចូលរួមរបស់ព្រះពុទ្ធសាសនាក្នុងការអភិវឌ្ឍន៍សង្គមជាតិលើគ្រប់វិស័យក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងក្រុងដូនកែវ ខេត្តតាកែវផ្ទាល់។ លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះក៏នឹងរកឱ្យឃើញពីចំណុចវិជ្ជមាន និង អវិជ្ជមាននៃការគ្រប់គ្រងនិងការប្រតិបត្តិព្រះពុទ្ធសាសនានៅកម្ពុជា ជាពិសេសក្នុងក្រុងដូនកែវតែម្ដង ដើម្បីបានជាឯកសារផ្លូវការសម្រាប់ធ្វើការវិភាគស្វែងរកចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមនានា ក្នុងការពង្រឹងពង្រីកព្រះពុទ្ធសាសនា និងកែប្រែធ្វើយ៉ាងណាឱ្យព្រះពុទ្ធសាសនាក្នុងក្រុងដូនកែវ មានការរីកចម្រើន និងមានសេចក្ដីថ្លៃថ្នូរ បានជាទីជ្រះថ្លានៃពុទ្ធបរិស័ទទូទៅក្នុងកម្ពុជរដ្ឋ។

លើសពីនេះទៅទៀត ឯកសារដែលបានពីការសិក្សាស្រាវជ្រាវលើប្រធានបទនេះ នឹងបន្សល់ទុកសម្រាប់អ្នកជំនាន់ក្រោយសិក្សាបន្តទៀត។ ការប្រមូលទិន្នន័យយកមកធ្វើជាអំណះអំណាងក្នុងការសិក្សាស្រាវជ្រាវនេះមានលក្ខណៈជាវិទ្យាសាស្ត្រ ផ្អែកសំខាន់ទៅលើទិន្នន័យអង្កេត (Primary Data) និងទិន្នន័យដែលមានស្រាប់ (Secondary Data)។ ទិន្នន័យអង្កេត ឬទិន្នន័យចម្បងប្រមូលបានពីអ្នកចូលរួមផ្ដល់ចម្លើយតាមរយៈការសម្ភាសផ្ទាល់មាត់ជាមួយព្រះគ្រូអនុគណក្រុង ព្រះមន្ត្រីសង្ឃសាលាអនុគណក្រុង ព្រះគ្រូចៅអធិការវត្ត គ្រូសូត្រឆ្វេង-ស្ដាំ មន្ត្រីរាជការ ពុទ្ធបរិស័ទ សិស្ស-និស្សិត និងការបំពេញកម្រងសំណួរដែលផ្ដោតលើកម្រងសំណួរដែលមានភ្ជាប់មកស្រាប់នៅក្នុងឧបសម្ព័ន្ធ ដែលសួរអំពីរបៀបនៃការគ្រប់គ្រងគណៈសង្ឃក្នុងក្រុងដូនកែវ កត្តាដែលនាំឱ្យការគ្រប់គ្រងគណៈសង្ឃបានល្អ ការប្រតិបត្តិព្រះពុទ្ធសាសនា និងសារៈសំខាន់ព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ។ ទិន្នន័យដែលមានស្រាប់ ត្រូវបានប្រមូលពីតាមបណ្ណាល័យនានា ពីសាស្ត្រាចារ្យ មិត្តភក្តិ វេបសាយផ្សេងៗ និងឯកសារដែលគេបានសិក្សាកន្លងមក។

ក្នុងការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជាសេចក្ដីផ្ដើម ជំពូកទី១ ជំពូកទី២ ជំពូកទី៣ និងសេចក្ដីសន្និដ្ឋាន។ នៅក្នុងសារណានេះមានសេចក្ដីផ្ដើមដែលលើកឡើងអំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។ ជំពូកទី១បានផ្ដោតសំខាន់លើទិដ្ឋភាពទូទៅនៃព្រះពុទ្ធសាសនា ចាប់តាំងពីកកើតឡើងដំបូងក្នុងប្រទេសឥណ្ឌា រហូតដល់ហូរចូលមកកាន់ដែនដី

សុវណ្ណភូមិ ជាពិសេសប្រទេសកម្ពុជា។ ជំពូកទី២ បានសិក្សាផ្ដោតជាសំខាន់លើគោលការណ៍គ្រប់គ្រងគណៈសង្ឃព្រះពុទ្ធសាសនានៅកម្ពុជា ជាពិសេសសិក្សាលើតួនាទី និងការកិច្ចនៃគណៈសង្ឃសាលាអនុគណក្រុង គណៈសង្ឃវត្ត និងការបំពេញតួនាទីរបស់ព្រះសង្ឃក្នុងការគ្រប់គ្រងដឹកនាំព្រះពុទ្ធសាសនាឱ្យមានការរីកចម្រើន។ ជំពូកទី៣ បានផ្ដោតការយកចិត្តទុកដាក់លើតួនាទីព្រះពុទ្ធសាសនា ក្នុងការចូលរួមចំណែកក្នុងកិច្ចការសង្គម ជាពិសេសការអភិវឌ្ឍន៍សង្គមជាតិ។ ការធ្វើសេចក្ដីសន្និដ្ឋាននៅក្នុងសារណានេះពឹងផ្អែកលើការស្រាវជ្រាវក្នុងជំពូកទី១ ជំពូកទី២ និងជំពូកទី៣ ដែលទាក់ទងទៅនឹងសំណួរស្រាវជ្រាវ។ គន្ថនិទ្ទេស បង្ហាញអំពីឯកសារពាក់ព័ន្ធនិងការសិក្សាស្រាវជ្រាវ ដែលបានបែងចែកជាពីរក្រុមគឺៈ ឯកសារជាភាសាជាតិ និងឯកសារជាភាសាបរទេស។ ឧបសម្ព័ន្ធបង្ហាញពីកម្រងសំណួរស្រាវជ្រាវ និងសកម្មភាពនៃការចុះស្រាវជ្រាវ រួមទាំងការធ្វើបទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធនានា។

# ABSTRACT

Research on the topic of "**Management and Practice of Buddhism in Cambodia**" (Case study of Daun Keo city from 2014 to 2019) aims to show that Buddhism is actively involved in building Social solidarity, illustrates the role of the monks in organizing the Sangha society in a dignified manner and in order to illustrates the Buddhist participation in national development in all sectors in the country, especially in Daun Keo City, Takeo. In addition, the study will explore the positives and negatives of Buddhist management and practice in Cambodia, especially in Daun Penh city, to become the official source for analyzing the strengths, weaknesses and challenges in order to promote Buddhism and reforming Buddhism in Daun Penh City for the Progress and dignity are the conscience of the general Buddhists in Cambodia.

In addition, the findings from the study will be available to future generations. The data collected in this study is scientifically based on the primary data and secondary data. Survey data or main data collected from participants giving answers through oral interviews such as the head of district Sangha council, Buddhist monk officials, municipalities, abode of pagodas, preachers, civil servants, Buddhists, students, and by fulfilling the questionnaires. The questionnaire which focuses on the inherent in the Appendix, which asks how the monks were governed in Doun keo city? What factors that lead to good management of the monkhood? what make a Buddhist practices good and bad? and the importance of Buddhism in Cambodian society. Existing data is collected from libraries, lecturers, friends from other websites, and past papers.

The research is divided into Introduction, Chapter 1, Chapter 2, Chapter 3 and Conclusion. In this thesis, there is an introduction that addresses the defaults of the research issue, the purpose of the research, the scope of the research, the importance of the research, and the structure of the research. The first chapter focuses on general teaching of Buddhism, the origin of Buddhism from its earliest date in India to the Suvarnabhumi territory, especially Cambodia. Chapter 2 focuses on the principles of Buddhist monastic rule in Cambodia, in particular on the role and duties of the head of district Sangha council, Buddhist monk officials, municipalities, abode of pagodas, preachers and their role in managing and leading Buddhism. Chapter 3 focuses on the role Buddhism plays in social work, especially national social development. The conclusions in this thesis based on research in chapters 1, chapter 2 and chapter 3 related to research questions. The bibliography presents research-related papers divided into two major groups: papers in national languages and foreign languages. The Appendix presents research questionnaires and research activities and interviews with stakeholders.

# សារណាសង្ខេប

ព្រះពុទ្ធសាសនាត្រូវបានបង្កើតឡើងដោយមហាបុរសមួយរូបនៅក្នុងប្រទេសឥណ្ឌា នៅក្នុងសតវត្សទី៦មុនគ្រិស្តសករាជ។ សាសនានេះមិនមែនជាសាសនាទេវនិយមទេ អ្នកប្រាជ្ញជាច្រើនក្នុងលោក ដែលមកពីបូព៌ាប្រទេសនិងបស្ចិមប្រទេសបានឯកភាពគ្នាប្រសិទ្ធិនាមថាជាសាសនាមនុស្សជាតិសុទ្ធសាធ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងនាមជាសាសនាដែលនិយាយអំពីសច្ចធម៌ ព្រះពុទ្ធសាសនាមានវិសាលភាពធំធេងណាស់ នៅលើគ្រប់វិស័យនៃជីវិតនិងការគិតរបស់មនុស្សជាតិ។ គំនិតនិងទស្សនៈសំខាន់របស់ព្រះពុទ្ធសាសនា បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអប់រំចិត្តគំនិតរបស់មនុស្សជាតិ ដែលនឹងដឹកនាំមនុស្សឱ្យរស់នៅក្នុងសេចក្តីសុខសន្តិភាពយ៉ាងពិតប្រាកដ។

ព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំមនុស្សឱ្យប្រព្រឹត្តនូវសីលធម៌ និងអកិសមាចារដ៏ប្រពៃដើម្បីភាពថ្លៃថ្នូរនិងសេចក្តីសុខស្ងប់ ប្រាសចាកការកាប់សម្លាប់ និងការប្រព្រឹត្តអំពើអនាចារផ្សេងៗ ដែលបង្កឱ្យមានភាពវឹកវរក្នុងសង្គម។ ព្រះពុទ្ធសាសនាបានណែនាំមនុស្សឱ្យមានសេចក្តីមេត្តាដែលជាសីលធម៌ដ៏កំពូល ដើម្បីរក្សាសន្តិភាព បុគ្គល គ្រួសារ សង្គម និងពិភពលោកទាំងមូល។

ទិដ្ឋភាពដ៏សំខាន់របស់ព្រះពុទ្ធសាសនាក្នុងឋានៈជាសាសនារបស់ពិភពលោកមួយ គឺឥរិយាបថនៃព្រះពុទ្ធសាសនាចំពោះបញ្ហាសង្គម បញ្ហាសេដ្ឋកិច្ច និងបញ្ហានយោបាយ។ល។ ជាទូទៅមនុស្សខ្វះចំណេះដឹងមួយចំនួន ច្រើនមាននិន្នាការដោយចាត់ទុកព្រះពុទ្ធសាសនាថាជាការគេចវេះ ឬដកខ្លួនថយពីជីវភាពដ៏សកម្ម ហើយទៅជ្រកពួនក្នុងព្រះវិហារ ឬក្នុងល្អាងភ្នំ ឬក៏ក្នុងព្រៃ ហើយដឹកនាំជីវភាពផ្តាច់ចេញពីសង្គម។ ទស្សនៈនេះបណ្តាលមកពីខ្វះសេចក្តីយល់ដឹង ខ្វះវិចារណញ្ញាណ ព្រោះព្រះពុទ្ធអង្គផ្ទាល់ជាបុគ្គលមួយរូបក្នុងចំណោមមនុស្សធ្វើការយ៉ាងសកម្ម និងខ្លាំងក្លាបំផុតដែលបានរស់នៅក្នុងលោកនេះ។

ផ្អែកលើមូលដ្ឋានដូចខាងលើនេះ ដើម្បីធ្វើឱ្យសង្គមទទួលបានសេចក្តីសុខសន្តិភាពពិតប្រាកដ ព្រះសង្ឃ ដែលជាសាវ័កផ្ទាល់របស់ព្រះពុទ្ធបានប្រតិបត្តិតាមគោលការណ៍ជាច្រើនរបស់ព្រះពុទ្ធសាសនា ដើម្បីអប់រំខ្លួន ណែនាំពុទ្ធបរិស័ទជាពិសេសការគ្រប់គ្រងនិងការប្រតិបត្តិព្រះពុទ្ធសាសនានៅកម្ពុជាបានក្លាយជាយន្តការដ៏សំខាន់ក្នុងការបន្តអត្ថិភាពព្រះពុទ្ធសាសនាឱ្យបានគ្រប់៥០០០ព្រះវស្សា។ ការគ្រប់គ្រងព្រះពុទ្ធសាសនាត្រូវបានអនុលោមទៅតាម គោលការណ៍ពីរសំខាន់គឺការគ្រប់គ្រងគណៈសង្ឃដោយយកធម៌វិន័យជាមូលដ្ឋានគ្រឹះ ស្របនឹងពុទ្ធវចនៈថា **"វិនយោ សាសនស្ស មូលំ"** វិន័យគឺជាឫសគល់នៃព្រះពុទ្ធសាសនា និងការគ្រប់គ្រងតាមបែបរដ្ឋបាល ដោយមានឋានានុក្រមគ្រប់លំដាប់ថ្នាក់ ផ្តើមចេញពីគណៈសង្ឃនាយក រាជាគណៈ គណៈសង្ឃខេត្ត គណៈសង្ឃស្រុក-ក្រុង ចុះមកក្រោមរហូតដល់គណៈសង្ឃវត្ត

ដែលមានព្រះគ្រូចៅអធិការជាប្រមុខដឹកនាំគ្រប់គ្រងសង្ឃដើម្បីសេចក្ដីល្អ និងសណ្ដាប់ធ្នាប់របស់ព្រះពុទ្ធសាសនាកម្ពុជាទាំងមូល។ ដោយឡែកនៅក្នុងការស្រាវជ្រាវនេះផ្ដោតលើគណៈសង្ឃស្រុក-ក្រុងត្រូវផ្ដល់អាទិភាពសំខាន់ ដើម្បីស្វែករកឱ្យឃើញពីវិសាលភាពនៃការគ្រប់គ្រងព្រះពុទ្ធសាសនានៅក្នុងកម្រិតមូលដ្ឋានថា តើមានភាពល្អប្រសើរកម្រិតណា បានយកគោលការណ៍អ្វីខ្លះមកអនុវត្តដឹកនាំនិងប្រតិបត្តិ។

ជាការពិតណាស់ អ្វីដែលបានរកឃើញពិតជាចំណុចដ៏សំខាន់ណាស់ដែល ត្រូវបានគណៈសង្ឃស្រុក-ក្រុងបានបំពេញដូចខាងក្រោម៖

**កិច្ចការរដ្ឋបាល** ៖ ការគ្រប់គ្រងគណៈសង្ឃតាមបែបរដ្ឋបាល ដោយមានកិច្ចការទំនាក់ទំនងគ្នាពីវត្តមួយទៅ វត្តមួយ ពីស្ថាប័នមួយទៅស្ថាប័នមួយទៀត តាមរយៈលិខិតរដ្ឋបាលជាផ្លូវការ ស្របតាមច្បាប់រដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា។

**ការបំពេញតួនាទីភារកិច្ច** ៖ គោលការណ៍ដ៏សំខាន់មួយទៀត គឺការបំពេញតួនាទី និងភារកិច្ចនៃសមាជិកគណៈសង្ឃគ្រប់លំដាប់ថ្នាក់សុទ្ធតែបានធ្វើឡើងត្រឹមត្រូវតាមរយៈសង្ឃប្រកាស និងការបែងចែកតួនាទីភារកិច្ចឲ្យច្បាស់លាស់ ដើម្បីជានាថារាល់សកម្មភាពរបស់ព្រះពុទ្ធសានាត្រូវបានបំពេញយ៉ាងល្អ។

**ការប្រតិបត្តិធម៌វិន័យ** ៖ កិច្ចការដ៏សំខាន់បំផុតរបស់គណៈសង្ឃគ្រប់លំដាប់ថ្នាក់ក្នុងព្រះរាជាណាចក្រកម្ពុជា គឺការតាមដានណែនាំនិងជំរុញការប្រតិបត្តិព្រះពុទ្ធសាសនានៅកម្ពុជាឱ្យបានត្រឹមត្រូវ ដើម្បីធានាដល់អាយុកាលនៃព្រះពុទ្ធសាសនាត្រូវបានបន្តតាមរយៈសទ្ធាដ៏មុតមាំរបស់ពុទ្ធបរិស័ទទាំងអស់។

**Thesis Summary**

Buddhism was founded by a great man in India in the 6th century BC. It is not a theistic religion. Many scholars from the East and the West agree that the religion is purely human. However, as a religion of truth, Buddhism has a huge scope in all areas of human life and thinking. The main idea and concept of Buddhism has been to focus on educating the human spiritual that will lead people to live in true happiness and peace.

Buddhism plays an important role in leading people to practice the highest morality and ethics for the dignity and peace of life, avoiding killing, and the acts of immorality that cause such chaos in society. Buddhism has introduced people to the highest moral standards for peace of mind, for the happiness of individual, family, society and the whole world.

One of the most important aspects of Buddhism as one of the world's religions is the attitude of Buddhism towards social, economic and political issues. In general, many educated people tend to view Buddhism as shunning or retreating from active life, taking refuge in temples or in caves, or in forests, and leading a detached life. This view is caused by a lack of understanding, a lack of investigation, because the Buddha himself is one of the most active human beings in the world.

On the basis of the above, in order to achieve true peace of mind, the monks who were the followers of the Buddha practiced the principles of Buddhism to educate themselves, in particular the practice of Buddhism. In Cambodia, it has become an important mechanism for the continued existence of Buddhism in all 5,000 years. This rainy. Buddhism is governed by two main principles: the management of the monks, based on the basic principles of Buddhism, and the principle, "Discipline is the root of which is Buddhism", and the administration of hierarchy. All levels start from the Supreme Patriarch of Cambodia monk, Supreme council of order, the royal order, the provincial and district order, and up to the abode of monastery. The abbot is the head of the monastic administration for the good and order of Buddhism in the Kingdom of Cambodia.

Particularly in this research, the focus of the district order is a priority to discovering the extent of Buddhist rule at the grassroots level, how well the principles are applied and implemented. Of course, what was found was an important point that was fulfilled by the district order:

**Administrative Affairs**: The management of the Buddhist monks in an administrative manner, with the tasks of communicating from one pagoda to another, through an official administrative letter in accordance with the administrative law of the Kingdom of Cambodia.

**Fulfillment of duties**: Another important principle is to fulfill the duties of the members of the Sangha at all levels, in accordance with the Buddhist Declaration and the division of duties in order to ensure that all Buddhist activities are performed well.

**Discipline of the Dharma**: The most important task of all levels of Buddhist monks in the Kingdom of Cambodia is to properly monitor, guide, and promote the practice of Buddhism in Cambodia to ensure the life of Buddhism is continued through its solidarity, confidence of all Buddhists.